(សេចក្តីព្រាង)

# របាយការណ៍
# វឌ្ឍនភាពការងារសម្រេចបានឆ្នាំ២០២៣ និងទិសដៅការងារឆ្នាំ២០២៤
# របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## ១. សេចក្តីផ្តើម

បច្ចុប្បន្ននេះ ស្ថានភាពសេដ្ឋកិច្ច និងនយោបាយសកលលោកស្ថិតក្នុងភាពផុយស្រួយ ដោយសារឥទ្ធិពល នៃវិបត្តិជំងឺកូវីដ-១៩ សង្គ្រាមរុស្ស៊ី-អ៊ុយក្រែន អ៊ីស្រាអែល-ហាម៉ាសប៉ាឡេស្ទីន និងការប្រែប្រួលអាកាសធាតុជាសាកល។ កត្តាទាំងនេះ កំពុងជះឥទ្ធិពលយ៉ាងខ្លាំងមកលើព្រះរាជាណាចក្រកម្ពុជា ដែលតម្រូវឱ្យមានដំណោះស្រាយប្រកបដោយភាពប៉ិនប្រសព្វ។ ជាភ័ព្វសំណាង កម្ពុជារក្សាបានសន្តិភាព និងស្ថេរភាពនយោបាយ ក្រោមការដឹកនាំដ៏ម៉ឺងម៉ាត់ និងប្រកបដោយគតិបណ្ឌិតរបស់បិតាសន្តិភាព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី ដែលបានផ្តល់ឱកាសសម្រាប់ការអភិវឌ្ឍប្រទេសជាតិស្របតាមក្របខណ្ឌយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤÷កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព។ ពិសេសកម្ពុជាបានធ្វើជាប្រធានអាស៊ានប្តូរវេន និងដឹកនាំកិច្ចប្រជុំកំពូលអាស៊ានបាន ៣ លើក (២០០២, ២០១២, ២០២២) ធ្វើជាម្ចាស់ផ្ទះប្រកួតកីឡាស៊ីហ្គេមលើកទី៣២, អាស៊ានប៉ារ៉ាហ្គេម លើកទី១២ ក្នុងឆ្នាំ ២០២៣ និងបានរៀបចំការបោះឆ្នោតជាតិជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៧ ប្រកបដោយភាពជោគជ័យ ដ៏ត្រចះត្រចង់ និងមានមោទនភាពយ៉ាងក្រៃលែង។

នៅក្នុងបុព្វហេតុ នៃការអភិវឌ្ឍប្រទេសឱ្យកាន់តែរីកចម្រើន រាជរដ្ឋាភិបាលកម្ពុជាក្នុងនីតិកាលទី ៧ នៃរដ្ឋសភា ដឹកនាំដោយ**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** បានបន្តយកចិត្តទុកដាក់ថែរក្សាសន្តិភាព និងស្ថេរភាពនយោបាយនៅក្នុងផ្ទៃប្រទេស ព្រមទាំងពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីស្ថេរភាពនយោបាយ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី ១÷ **កំណើន ការងារ សមធម៌ ប្រសិទ្ធភាព** និង**ចីរភាព** ព្រមទាំងបានកំណត់អាទិភាពគន្លឹះចំនួន ៥ គឺ **មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា** ដែលជាមូលដ្ឋានសម្រាប់ការរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រតាមវិស័យ ក្នុងគោលដៅអភិវឌ្ឍន៍កម្ពុជាឱ្យក្លាយទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

ជាមួយនឹងចក្ខុវិស័យ និងយុទ្ធសាស្ត្រខាងលើនេះ ក្រសួងអភិវឌ្ឍន៍ជនបទ បានដាក់ចេញនូវគោលនយោបាយអភិវឌ្ឍន៍ជនបទ ដែលមានគោលបំណងប្រែក្លាយតំបន់ជនបទ នៃកម្ពុជាឱ្យក្លាយជាតំបន់អភិវឌ្ឍន៍ រីកចម្រើនប្រកបដោយបរិយាបន្ន និងមាននិរន្តរភាព។ នៅក្នុងន័យនេះ ក្រសួងបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទរយៈពេល ៥ ឆ្នាំជាបន្តបន្ទាប់ ជាអាទិ៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ ៥ឆ្នាំ (២០១៩-២០២៣) មានគោលបំណង **"លើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរស់នៅរបស់ប្រជាជននៅតំបន់ជនបទប្រកបដោយបរិយាបន្នទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌"** ដោយបានកំណត់យុទ្ធសាស្ត្រចំនួន៤ គឺ÷ ១. អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍ ២.លើកកម្ពស់លក្ខខណ្ឌ នៃការរស់នៅរបស់សហគមន៍ជនបទ ៣.ធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ និង៤. ពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅ ក្នុងគោលដៅលើកកម្ពស់សមត្ថភាពធនធានមនុស្ស និងស្ថាប័ន។

ស្របជាមួយនឹងយុទ្ធសាស្ត្រទាំង៤ ខាងលើនេះ ក្រសួងបានរៀបចំផែនការអនុវត្តប្រចាំឆ្នាំ ដោយកំណត់កម្មវិធីអាទិភាពចំនួន៤ អនុកម្មវិធីចំនួន២១ និងចង្កោមសកម្មភាពចំនួន១៧៤ ទទួលបានលទ្ធផលដូចខាងក្រោម÷

## ២. លទ្ធផលនៃការអនុវត្តកម្មវិធីអាទិភាពទាំង៤

### ២.១. អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍ជនបទ

ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍ដឹកជញ្ជូននៅជនបទមានសារៈសំខាន់បំផុតក្នុងការជំរុញដំណើរអន្តរកម្មផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ចនៅតំបន់ជនបទ និងកាត់បន្ថយគម្លាតរវាងតំបន់ជនបទ និងទីប្រជុំជន។ ការស្ថាបនា ការស្តារ ការថែទាំ និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត គឺជាការវិនិយោគដ៏ចាំបាច់ ដើម្បីសម្រួលដល់គមនាគមន៍ និងការផ្តល់សេវាសាធារណៈផ្សេងៗជូនដល់ប្រជាជនគ្រប់ទិសទីនៅទូទាំងប្រទេស ដែលជាចំណែកដ៏សំខាន់ក្នុងការលើកកម្ពស់ជីវភាពរស់នៅ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ ក្នុងន័យនេះ ក្រសួងបាន និងកំពុងផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងលើការស្ថាបនាផ្លូវជនបទ ដោយគិតគូរពីភាពធន់នឹងការប្រែប្រួលអាកាសធាតុ រួមមានផ្លូវដីស ផ្លូវល្បាយក្រួស និងផ្លូវកៅស៊ូពីរជាន់ ឬក្រាលបេតុង ដើម្បីបង្កភាពងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការធ្វើដំណើរ, ចំណេញពេលវេលា, កាត់បន្ថយការចំណាយលើការដឹកជញ្ជូនសម្ភារ ឬផលិតផលផ្សេងៗទៅកាន់ទីផ្សារ និងងាយស្រួលក្នុងការទទួលបាននូវសេវាសាធារណៈ។

ជាលទ្ធផលគិតត្រឹមឆ្នាំ២០២៣ ក្រសួងបានស្ថាបនា ស្តារ និងកែលម្អផ្លូវជនបទសរុបប្រវែង ៥០ ២៦២គ.ម និងបានចងក្រងជាបញ្ជីសារពើភ័ណ្ឌ និងប្រព័ន្ធគ្រប់គ្រងផ្លូវជនបទរួចរាល់ក្នុងនោះមាន÷

– ផ្លូវក្រាលកៅស៊ូពីរជាន់ប្រវែង ៥ ៤៤៧គ.ម ផ្លូវក្រាលបេតុងប្រវែង ១ ៤៧១គ.ម ផ្លូវល្បាយក្រួសប្រវែង ៣១ ០០៨គ.ម និងផ្លូវដីសប្រវែង ១២ ៣៣៦គ.ម

- សំណង់សិល្បការគ្រប់ប្រភេទសរុបចំនួន ៤៨ ៨២២កន្លែង គិតជាប្រវែងសរុបជិត ៣២គ.ម (ស្ពានបេតុងចំនួន ២ ៣០៣កន្លែង សរុបប្រវែង ២៨គ.ម ស្ពានដែកចំនួន ៨៣កន្លែង សរុបប្រវែង ២គ.ម ស្ពានឈើចំនួន ១២៦កន្លែង សរុបប្រវែង ២គ.ម លូមូលសរុបចំនួន ៣៦ ១២៨កន្លែង លូប្រអប់ចំនួន ៤ ០៦៣កន្លែង និងសំណង់សិល្បការផ្សេងៗចំនួន ៦ ១១៩កន្លែង)។

ដោយឡែកក្នុងឆ្នាំ២០២៣នេះ ក្រសួងអនុវត្តកម្មវិធីទី១ សម្រេចបាន ៩៧% នៃផែនការ÷

- បានថែទាំផ្លូវជនបទចំនួន ៤៨៣ខ្សែ ប្រវែង ៤ ៣៧២ គ.ម. ការស្តារនីតិសម្បទាពង្រីកវិសាលភាព និងកែលម្អលើកកម្រិតផ្លូវជនបទចំនួន ៩៥ខ្សែ ប្រវែង ៤៤៧គ.ម. សាងសង់សំណង់សិល្បការគ្រប់ប្រភេទបានចំនួន ១៣៧១កន្លែង និងបំពាក់ស្លាកសញ្ញាចរាចរណ៍ចំនួន ២ ៧៨៣ស្លាក ព្រមទាំងស្តារនីតិសម្បទាផ្លូវល្បាយក្រួស ក្រោមគម្រោងសាច់ប្រាក់ពលកម្មបានប្រវែង ៩៩១គ.ម.
- បានកែលម្អផ្លូវជនបទក្រោមគម្រោងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍សរុប ១ ៦៣០ គ.ម.
- បានជួសជុលផ្លូវជនបទលក្ខណៈបន្ទាន់ចំពោះផ្លូវ ដែលរងការខូចខាតដោយសារទឹកជំនន់ ដើម្បីតភ្ជាប់ឡើងវិញចំនួន ១២១ ករណី ប្រវែងជាង ២០៨គ.ម. ជួសជុលលូមូលបានចំនួន ៦កន្លែង និងជួសជុលស្ពានបានចំនួន ៣កន្លែង។ នៅក្នុងឆ្នាំ ២០២៣នេះ ហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ ដែលទទួលរងផលប៉ះពាល់ដោយសារទឹកជំនន់មាន ២៥៦ខ្សែ ប្រវែងសរុប ២ ១០៨គ.ម. ក្នុងនោះ ផ្លូវលិចទឹកប្រវែងជាង ៣៣៧គ.ម. ដាច់តួផ្លូវប្រវែងជាង ១២៨គ.ម. ដាច់ជើងទេរប្រវែងជាង ១៧១គ.ម. បាក់ស្រុតស្ពានចំនួន ៨កន្លែង ខូចលូប្រអប់ចំនួន ៣កន្លែង និងលូមូលចំនួន ២០កន្លែង។

ជារួមកម្មវិធីអាទិភាពទី ១ របស់ក្រសួងបានផ្តោតសំខាន់ទៅលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ ដែលជាតម្រូវការចាំបាច់សម្រាប់ជំរុញចលនាសេដ្ឋកិច្ចនៅតំបន់ជនបទ តាមរយៈការតភ្ជាប់ផ្លូវជនបទឱ្យមានលក្ខណៈប្រទាក់ក្រឡាគ្នា ជាពិសេសនៅតំបន់ផលិតកម្ម ដើម្បីជួយសម្រួលដល់ការដឹកជញ្ជូន និងការធ្វើគមនាគមន៍របស់ប្រជាពលរដ្ឋសម្រាប់ការទំនាក់ទំនងសេដ្ឋកិច្ច និងសង្គម ព្រមទាំងទទួលបានសេវាសាធារណៈនានា នៅគ្រប់រដូវកាល ដោយចំណេញពេលវេលា និងកាត់បន្ថយការចំណាយ។ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍ជនបទ គឺជាគន្លឹះគាំទ្រដល់រាល់កម្មវិធីកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ។ ប៉ុន្តែការប្រឈមក្នុងការវិនិយោគទៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធ គឺត្រូវការថវិកាច្រើន ជាពិសេសការធានាគុណភាពឱ្យធន់នឹងការប្រែប្រួលអាកាសធាតុ ដែលពិភពលោកទាំងមូលកំពុងជួបប្រទះ។ យោងតាមរបាយការណ៍របស់ធនាគារពិភពលោកស្តីពីស្ថានភាពអាកាសធាតុ និងការអភិវឌ្ឍនៅកម្ពុជា ចុះផ្សាយកាលពីខែកញ្ញា ឆ្នាំ២០២៣នេះ បានលើកឡើងថា ការប្រែប្រួលអាកាសធាតុអាចធ្វើឱ្យ GDP ធ្លាក់ចុះ ៩% គិតត្រឹមឆ្នាំ២០៥០ និងអត្រានៃភាពក្រីក្រកើនឡើង ៦% គិតត្រឹមឆ្នាំ ២០៤០ ប្រសិនបើពុំមានដំណោះស្រាយទេ។ មួយក្នុងចំណោមដំណោះស្រាយ ដែលអាចចូលរួមក្នុងការកាត់បន្ថយហានិភ័យនេះបាន គឺការបង្កើននូវបណ្តាញផ្លូវតភ្ជាប់ និងសាងសង់ផ្លូវឱ្យធន់នឹងការប្រែប្រួល

អាកាសធាតុ ដើម្បីធានាប្រសិទ្ធភាពនៃការប្រើប្រាស់ផ្លូវជនបទបានយូរអង្វែង និងគ្រប់រដូវកាល ដើម្បីការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងវប្បធម៌នៅតំបន់ជនបទ។

## ២.២. កែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ

សុខភាព និងបរិស្ថានរស់នៅល្អជាកត្តាដ៏សំខាន់សម្រាប់ប្រជាជននៅតំបន់ជនបទ ដែលក្រសួងបាន និងកំពុងយកចិត្តទុកដាក់ ដើម្បីជួយឱ្យប្រជាពលរដ្ឋមានសុខភាពល្អប្រសើរ តាមរយៈការអនុវត្តអនាម័យផ្ទាល់ខ្លួនតាមក្បួនខ្នាតត្រឹមត្រូវ ដើម្បីជៀសផុតពីជំងឺផ្សេងៗ និងអាយុកាលសង្ឃឹមរស់ជាមធ្យមរបស់ប្រជាជន(Life Expectancy) កាន់តែខ្ពស់ដែលជាក្តីប្រាថ្នារបស់មនុស្សគ្រប់រូប។ ក្នុងន័យនេះ ក្រសួងបាន និងកំពុងផ្តល់សេវាផ្គត់ផ្គង់ទឹក និងអនាម័យជនបទ តាមរយៈការជីក និងស្តារស្រះសហគមន៍ ខួងអណ្តូង ផ្តល់ពាងយក្ស សាងសង់អាងត្រងទឹកភ្លៀង សាងសង់ប្រព័ន្ធចែកចាយទឹកតាមបំពង់សហគមន៍ខ្នាតតូច សាងសង់ស្ថានីយ៍ផលិតទឹកស្អាតសហគមន៍ ផ្តល់ធុងចម្រោះទឹកស្អាត សាងសង់បង្គន់អនាម័យ និងអប់រំអំពីអនាម័យ និងការសម្អាត។ ជាលទ្ធផលគិតត្រឹមឆ្នាំ២០២៣ រួមមាន÷

**ក. ការងារផ្គត់ផ្គង់ទឹកជនបទ÷**

- បានសាងសង់អណ្តូងចំនួន ៦៣៧ ២៣៧អណ្តូង, បានជួសជុលអណ្តូងចំនួន ៧ ៣៣២អណ្តូង, បានសាងសង់ស្រះសហគមន៍ចំនួន ១០ ៥៤៦ស្រះ, បានសាងសង់អាងត្រងទឹកភ្លៀងចំនួន ៥៨ ៥៥៩អាង និងបានផ្តល់ពាងយក្សចំនួន ២៦៩ ៣៨៤ពាង
- បានសាងសង់ស្ថានីយ៍ផលិតទឹកផឹកសហគមន៍ចំនួន ១៤០ស្ថានីយ៍, បានសាងសង់ប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍ចំនួន ៤០៧ប្រព័ន្ធ, និងបានជួសជុលប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍ចំនួន ១ប្រព័ន្ធ
- បានផ្តល់ធុងចម្រោះទឹកស្អាតចំនួន ១២៤ ៥១១ធុង បានសាងសង់អាងត្រងទឹកភ្លៀងផ្លាស្ទិកចំណុះ ១០ ០០០លីត្រ ចំនួន ១៥០អាង និងបានសាង់សង់ស្ថានីយ៍ស្រូបយកទឹកពីបរិយាកាស (Air to Water) ចំនួន ៥ស្ថានីយ៍
- បានបណ្តុះបណ្តាលបច្ចេកទេសថែទាំ និងជួសជុលអណ្តូងចំនួន ២៧វគ្គ អ្នកចូលរួម ១ ០៣៦នាក់
- អប់រំ និងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យយល់ដឹងពីការប្រើប្រាស់ទឹកស្អាតចំនួន ៤៣វគ្គ មានអ្នកចូលរួម ១៥៤០នាក់ និងប្រារព្ធទិវាទឹកពិភពលោកចំនួន ៣លើក មានអ្នកចូលរួមចំនួន ៩០០នាក់
- បានបណ្តុះបណ្តាលស្តីពី ផែនការសុវត្ថិភាពទឹកជនបទ ៥៧លើកមានអ្នកចូលរួម ៣ ៨៧២នាក់
- បានសាងសង់ប្រព័ន្ធស្រោចស្រពខ្នាតតូច និងថាមពលខ្នាតតូច ចំនួន ១៦ខ្សែ។

**ខ. ការងារលើកកម្ពស់អនាម័យជនបទ÷**

- បានសាងសង់បង្គន់គ្រួសារចំនួន ២ ៥៨៣ ២៥៨បង្គន់ ក្នុងនោះបង្គន់អនាម័យនៅតំបន់លិចទឹកចំនួន ៩១០បង្គន់ និងបានសាងសង់បង្គន់អនាម័យសាធារណៈចំនួន ១០ ៣២២ខ្នង

- បានបណ្តុះបណ្តាល និងផ្សព្វផ្សាយគោលការណ៍ណែនាំដល់មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ចំនួន ២ ៧៦៩វគ្គ មានអ្នកចូលរួមចំនួន ១២៣ ៤៣៧នាក់ លើការងារលើកកម្ពស់អនាម័យជនបទ
- បានចុះអប់រំផ្សព្វផ្សាយជំរុញប្រជាពលរដ្ឋឱ្យប្រតិបត្តិអនាម័យល្អទាំង៣ (ការសាងសង់ និងការប្រើប្រាស់បង្គន់អនាម័យ, ការលាងសម្អាតដៃនឹងសាប៊ូក្រោយពេលបន្ទោបង់ និងមុនពេលបរិភោគអាហារ និងការផឹកទឹកមានសុវត្ថិភាព) ចំនួន ៦ ៧៧៨លើក មានអ្នកចូលរួមសរុប ៤៧២ ៧៩៤នាក់។

ដោយឡែកនៅក្នុងឆ្នាំ២០២៣ ក្រសួងបានបន្តអនុវត្តយ៉ាងហ្មត់ចត់លើផែនការសកម្មភាពជាតិស្តីពីការផ្គត់ផ្គង់ទឹក ការសម្អាត និងអនាម័យជនបទដំហានទី២ (២០១៩-២០២៣) ដោយកំណត់គោលដៅអត្រាគ្របដណ្តប់ចំនួន ៩០% នៅត្រឹមឆ្នាំ ២០២៣។ ជាក់ស្តែង ក្រសួងសម្រេចបានលទ្ធផលទាបជាងការរំពឹងទុក ពោលគឺកើនឡើងបានត្រឹមតែ ៨៦% [មានការកើនឡើងបើធៀបអត្រាក្នុងឆ្នាំ២០២២ មានត្រឹម ៨៣% (MIS Q4-2022)] ដោយសារវិបត្តិជំងឺកូវីដជាសាកល និងបញ្ហាសង្គ្រាម ដែលបានជះឥទ្ធិពលជាអវិជ្ជមានមកលើការអភិវឌ្ឍសេដ្ឋកិច្ចក្នុងពិភពលោក ក៏ដូចជានៅប្រទេសកម្ពុជាផងដែរ។

ជាលទ្ធផលសម្រេចបានក្នុងឆ្នាំ ២០២៣÷

**ក. ការងារផ្គត់ផ្គង់ទឹកជនបទ**

- បានសាងសង់អណ្តូងចំនួន ២ ០១៦អណ្តូង ថវិកាកម្មវិធីចំនួន ៣៤៩អណ្តូង, គម្រោងដៃគូចំនួន ៧៥៩អណ្តូង, និងNGOs ចំនួន ៩០៨អណ្តូង និងជួសជុលអណ្តូងចំនួន ១៥១អណ្តូង ដោយ NGOs និងសាងសង់ស្រះសហគមន៍ចំនួន ៣១៦ស្រះ ថវិកាកម្មវិធីចំនួន ៦ស្រះ, គម្រោងដៃគូចំនួន ២១ស្រះ, និង NGOs ចំនួន ២៨៩ស្រះ
- សាងសង់អាងត្រងទឹកភ្លៀងចំនួន ១០៥អាង ថវិកាកម្មវិធីចំនួន ៣៨អាង និងគម្រោងដៃគូចំនួន ៦៧អាង និងសាសង់ស្ថានីយ៍ផលិតទឹកផឹកសហគមន៍ចំនួន ២ស្ថានីយ៍ ថវិកាកម្មវិធីចំនួន ១ស្ថានីយ៍ និងគម្រោងដៃគូចំនួន ១ស្ថានីយ៍
- សាងសង់ប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍ចំនួន ១២៧កន្លែង ថវិកាកម្មវិធីចំនួន ៤កន្លែង និង NGOs ចំនួន ១២៣កន្លែង និងផ្តល់ពាងទឹកចំនួន ៦៤ ៨១២ពាង គម្រោងដៃគូចំនួន ៤៥ ២១១ពាង NGOs ១៩ ៦០១ពាង និងផ្តល់ធុងចម្រោះ ២៧ ៨៨៣ធុង ដោយNGOs
- បានបណ្តុះបណ្តាល ស្តីពីបច្ចេកទេសថែទាំ និងជួសជុលអណ្តូងចំនួន ១វគ្គ មានអ្នកចូលរួមចំនួន ១១៥នាក់ និងបានបណ្តុះបណ្តាលស្តីពី ការអប់រំប្រជាពលរដ្ឋឱ្យយល់ដឹងពីការប្រើប្រាស់ទឹកស្អាតចំនួន ៤វគ្គ នៅរាជធានីភ្នំពេញ និងខេត្តរតនគិរី មានអ្នកចូលរួមចំនួន ១៩៦នាក់
- បានរៀបចំសិក្ខាសាលាស្តីពី ការរៀបចំផែនការសុវត្ថិភាពទឹកផឹកជនបទចំនួន ១០វគ្គ នៅរាជធានីភ្នំពេញ ខេត្តបាត់ដំបង និងខេត្តស្វាយរៀង មានអ្នកចូលរួមចំនួន ៥៦៩នាក់
- បានសាងសង់ប្រព័ន្ធស្រោចស្រពខ្នាតតូចចំនួន ២ខ្សែ

- បានចុះធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារទឹកស្អាតជនបទទាំង ២៥រាជធានី ខេត្ត។

**ខ. ការងារលើកកម្ពស់អនាម័យជនបទ÷**

- បានសាងសង់បង្គន់អនាម័យគ្រួសារតាមរយៈថវិកាកម្មវិធី អង្គការ និងគម្រោងដៃគូនានា ចំនួន ២៨ ៦៤១បង្គន់ និងបង្គន់អនាម័យសាធារណៈចំនួន ៧៨ខ្នង ដោយគម្រោងដៃគូ
- សាងសង់កន្លែងលាងសម្អាតដៃសាធារណៈ ចំនួន ២ ៣៩៩កន្លែង ដោយ NGOs
- រៀបចំបញ្ជីវឌ្ឍនភាពបង្គន់អនាម័យនៅតាមភូមិគោលដៅដែលបានសាងសង់បង្គន់អនាម័យ ចំនួន ១៧៦ភូមិ នៅខេត្តគោលដៅចំនួន ១៦ខេត្ត
- បានបណ្តុះបណ្តាល និងផ្សព្វផ្សាយគោលការណ៍ណែនាំដល់មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ចំនួន ៩៣វគ្គ (ថវិកាកម្មវិធីចំនួន ៣៩វគ្គ មានអ្នកចូលរួមចំនួន ១ ៦០០នាក់ និងNGOs ចំនួន ៥៤វគ្គ មានអ្នកចូលរួមចំនួន ២ ៧៣៥នាក់) លើការងារលើកកម្ពស់អនាម័យជនបទ
- បានចុះអប់រំផ្សព្វផ្សាយជំរុញប្រជាពលរដ្ឋឱ្យប្រតិបត្តិអនាម័យល្អទាំង៣ (ការសាងសង់ និងការប្រើប្រាស់បង្គន់អនាម័យ, ការលាងសម្អាតដៃនឹងសាប៊ូក្រោយពេលបន្ទោបង់ និងមុនពេលបរិភោគអាហារ និងការផឹកទឹកមានសុវត្ថិភាព) ចំនួន ៣១៣លើក (ថវិកាកម្មវិធីចំនួន ១០១លើក មានអ្នកចូលរួម ៧ ៨៣០នាក់ និង NGOs ចំនួន ២១២លើក មានអ្នកចូលរួម ១៥ ៩៧៨នាក់)
- បានអនុវត្តកម្មវិធី "បញ្ចប់ការបន្ទោបង់ពាសវាលពាសកាល" (Open Defecation Free-ODF) បាន ៧ ៣៩៧ភូមិនៅក្នុង ៦៥៤ឃុំ, ៥៩ស្រុក និង ៦ខេត្ត រួមមានខេត្តស្វាយរៀង ព្រៃវែង កណ្តាល កំពង់ស្ពឺ កំពង់ឆ្នាំង និងខេត្តកែប (ទិន្នន័យ MIS Q3 2023)
- បានប្រារព្ធទិវាជាតិលើកកម្ពស់អនាម័យជនបទនៅថ្ងៃ១៣ ខែវិច្ឆិកា ដើម្បីជាសារក្រើនរំលឹកដាស់តឿនដល់បងប្អូនប្រជាពលរដ្ឋ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ឱ្យយល់ដឹងអំពីសារៈសំខាន់ និងចូលរួមធ្វើឱ្យកាន់តែសកម្មក្នុងការលើកកម្ពស់ស្ថានភាពអនាម័យនៅតំបន់ជនបទ ឈានទៅសម្រេចតាមគោលដៅកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៧÷"**ការកសាង និងការការពារមាតុភូមិឆ្នាំ (២០២៣ - ២០២៨)**" ក្នុងការបន្តជំរុញការអនុវត្តផែនការសកម្មភាពជាតិស្តីពី ការផ្គត់ផ្គង់ទឹក និងអនាម័យជនបទឱ្យសម្រេចអត្រាគ្របដណ្តប់ ១០០% នៅឆ្នាំ២០៣០។

ជារួមការកែលម្អលក្ខខណ្ឌ នៃការរស់នៅរបស់សហគមន៍ជនបទ តាមរយៈសកម្មភាពផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ជាគន្លឹះក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ដោយជួយឱ្យប្រជាពលរដ្ឋរស់នៅមានសុខភាពល្អ និងបរិស្ថានស្អាតប្រកបដោយផាសុកភាព។ ជាមួយនឹងលទ្ធផលគួរឱ្យកត់សម្គាល់ខាងលើនេះ ក្រសួងនឹងបន្តបេសកកម្មផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យជនបទ ដើម្បីជួយប្រជាពលរដ្ឋរស់នៅប្រកបដោយសុខភាពល្អ ដែលអាចក្លាយជាមូលធនមនុស្សសម្រាប់បន្តការអភិវឌ្ឍប្រទេសជាតិទៅអនាគត។

## ២. ៣. ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ

ក្រសួងបានអនុវត្តកម្មវិធីពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ យ៉ាងសកម្មនៅតាមតំបន់ជនបទ ក្នុងគោលដៅចូលរួមបង្កើតឱកាសការងារ មុខរបរ សហគ្រិនភាព និងទីផ្សារ ក៏ដូចជាបង្កើនសកម្មភាពសេដ្ឋកិច្ចនានា ក្រោមរូបភាពមុខរបរកសិកម្ម និងមុខរបរមិនមែនកសិកម្ម។ ការធ្វើពិពិធកម្មសេដ្ឋកិច្ចជនបទជាចំណែកមួយក្នុងការបង្កើនឱកាសការងារ និងកាត់បន្ថយការធ្វើចំណាកស្រុកទៅកាន់ទីក្រុង ឬឆ្លងដែនដោយប្រថុយប្រថាន ព្រមទាំងជំរុញឱ្យមានការផ្លាស់ប្តូរស្ថានភាពរស់នៅឱ្យបានល្អប្រសើរ។ ទន្ទឹមគ្នានេះ ការអភិវឌ្ឍ និងអភិរក្សសហគមន៍ជនជាតិដើមភាគតិច ក្រសួងក៏បានយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ស្របតាមគោលនយោបាយអភិវឌ្ឍន៍ជនជាតិដើមភាគតិច ដោយគោរពនូវសេចក្តីថ្លៃថ្នូរ អត្តសញ្ញាណ វប្បធម៌ ទំនៀមទម្លាប់ និងប្រពៃណីរបស់ជនជាតិដើមភាគតិចនីមួយៗនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

ជាលទ្ធផលសម្រេចបានគិតត្រឹមឆ្នាំ២០២៣ រួមមាន÷

### ក. ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ÷

- គម្រោងឥណទានរបស់ក្រសួងមានទ្រព្យសកម្មសរុបចំនួន ២ ៣០១ ៧៩១ ១៤៥រៀល (ពីរប៊ីលានបីរយមួយលាន ប្រាំពីររយកៅសិបមួយពាន់ មួយរយសែសិបប្រាំរៀល) សម្រាប់ផ្តល់ឥណទានដល់ប្រជាជននៅតំបន់ជនបទ ដោយមានអ្នកខ្ចីសរុបចំនួន ៨១៧នាក់ នៅក្នុងភូមិគោលដៅចំនួន ៨១ភូមិ ៤១ឃុំ ២៣ស្រុកក្នុងខេត្តចំនួន ៩ គឺខេត្តកំពង់ចាម ត្បូងឃ្មុំ តាកែវ បាត់ដំបង កំពង់ធំ ស្ទឹងត្រែង ព្រះសីហនុ កំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង
- ផ្តល់ឥណទានមិនមែនសាច់ប្រាក់ (ធនាគារគោចំនួន ១៣១ក្បាល)
- បានចងក្រងសហគមន៍សន្សំប្រាក់ចំនួន ២២២ ៥៤៣នាក់ ត្រូវជា ១២ ៤៧៥ក្រុម (ដោយមានកិច្ចសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលចំនួន ១១អង្គការ)
- បានសាងសង់ផ្សារសហគមន៍ចំនួន ៦ផ្សារ និងបានរៀបចំតាំងពិព័រណ៍ផលិតផលជនបទ ក្រោមប្រធានបទ«ភូមិខ្ញុំផលិតផលខ្ញុំ» ចំនួន ៥លើក
- បានបណ្តុះបណ្តាលពីបច្ចេកទេសផលិតសាប៊ូបានចំនួន ១ ៣៥៩នាក់ និងបានបង្កើតសិប្បកម្មបានចំនួន ៥៨កន្លែង និងបានបណ្តុះបណ្តាលបច្ចេកទេសផលិតឡជីវឧស្ម័ន ត្បាញក្រម៉ា ត្បាញហូល ចិញ្ចឹមត្រី ផ្តល់ពូជត្រី ផ្តល់ពូជមាន់ មានចំនួន ៦១៦នាក់
- បានរៀបចំសិក្ខាសាលាស្តីពី គំនិតផ្តួចផ្តើម និងការគ្រប់គ្រងអាជីវកម្មខ្នាតតូច មានអ្នកចូលរួមចំនួន ៤១៥នាក់។

### ខ. ការងារអភិវឌ្ឍន៍សហគមន៍÷

- បានផ្សព្វផ្សាយសារាចរណែនាំស្តីពី ការបង្កើត និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការអភិវឌ្ឍន៍

ភូមិ (គ.អ.ភ) មានអ្នកចូលរួមចំនួន ៤ ៣៤៧នាក់ និងចែកសៀវភៅសារាចរណែនាំចំនួន ២៦០០ក្បាល ព្រមទាំងបានបង្កើត គ.អ.ភ ក្នុងក្របខណ្ឌទូទាំងប្រទេស

- បានបណ្តុះបណ្តាល គ.អ.ភ ចំនួន ១៣ ៧៣០ភូមិ ក្នុងនោះមានការបណ្តុះបណ្តាលមុនចេញសេចក្តីប្រកាសអន្តរក្រសួង ស្តីពីការបង្កើត គ.អ.ភ (ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងមហាផ្ទៃ) ចំនួន ៥ ២៦៩ភូមិ និងក្រោយចេញប្រកាសអន្តរក្រសួងចំនួន ៨ ៤៦១ភូមិ
- បានរៀបចំសិក្ខាសាលាផ្លាស់ប្តូរបទពិសោធន៍ការងារពង្រឹងសមត្ថភាព គ.អ.ភ បានចំនួន ១១លើក អ្នកចូលរួមចំនួន ១ ២៣០នាក់ និងរៀបចំសិក្ខាសាលាចែករំលែកបទពិសោធន៍ស្តីពី គោលគំនិតនៃការអភិវឌ្ឍសហគមន៍ចំនួន ១លើក អ្នកចូលរួមចំនួន ៩០នាក់
- បានអភិវឌ្ឍន៍ភូមិចម្រុះចំនួន ៩៣ភូមិ តាមរយៈការផ្តល់ស្រះគ្រួសារចំនួន ៤៨៣ស្រះ ផ្តល់កូនត្រីសម្រាប់ចិញ្ចឹមចំនួន ៧៤ ៨៧០ក្បាល ផ្តល់កូនឈើហូបផ្លែ និងកូនឈើចម្រុះចំនួន ៥៩ ៩៤៥ ដើម មេជ្រូកចំនួន ២៩០ក្បាល ពូជមាន់ចំនួន ៦ ១៩៥ក្បាល ស្រូវពូជ ២ ៨២៥គ.ក ពូជពោតក្រហមចំនួន ២០០គ.ក និងផ្តល់សម្ភារធ្វើរោងជីកំប៉ុស្ត និងបន្លែចម្រុះចំនួន ៧៣៥២គ្រួសារ
- បានអភិវឌ្ឍន៍ភូមិគំរូចំនួន ៦៤ភូមិ ក្នុងនោះ ៣០ភូមិ បានបញ្ចប់សកម្មភាពគាំទ្រ និង៣៤ភូមិកំពុងទទួលបានការគាំទ្រនៅក្នុងខេត្តកំពង់ស្ពឺ តាកែវ ត្បូងឃ្មុំ បាត់ដំបង បន្ទាយមានជ័យ និងខេត្តប៉ៃលិន
- បានបណ្តុះបណ្តាលសន្តិសុខស្បៀងជាលក្ខណៈគ្រួសារសម្រាប់គ្រូបង្គោលមន្ត្រីថ្នាក់ខេត្តចំនួន ២០នាក់, បណ្តុះបណ្តាលសួនដំណាំគ្រួសារ និងរបៀបធ្វើជីកំប៉ុស្តដល់គ្រួសារសហគមន៍ចំនួន ៩៨វគ្គ មានអ្នកចូលរួម ២ ២៥៥នាក់
- បានបណ្តុះបណ្តាលការអប់រំក្រៅប្រព័ន្ធ ស្តីពីអក្ខរកម្មចំនួន ២៥៦៧នាក់ និងបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការត្រៀមបង្ការ និងកាត់បន្ថយហានិភ័យចំនួន ៨១វគ្គ អ្នកចូលរួម ២ ៦៧០នាក់
- បានបណ្តុះបណ្តាលភាពជាអ្នកដឹកនាំកម្រិតភូមិ និងផ្នែកកសិកម្មផ្តោតលើការចិញ្ចឹមសត្វ ដាំបន្លែកែច្នៃម្ហូបអាហារ និងចលនាភូមិថ្មីចំនួន ៩៤វគ្គ មានអ្នកចូលរួម ២ ៦១៥នាក់។

**គ. ការងារបណ្តុះបណ្តាល ធនធានមនុស្ស និងជំនាញអាជីព÷**

- បានបណ្តុះបណ្តាលមន្ត្រីរាជការទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៅក្នុងប្រទេសបានចំនួន ១៨ ៦២៣លើក មានមន្ត្រីចូលរួមសរុប ៥៨ ០២១នាក់ និងក្រៅប្រទេសចំនួន ៦៥០លើក មានអ្នកចូលរួមសរុបចំនួន ១ ១១២នាក់
- បានផ្តល់ការបណ្តុះបណ្តាលជំនាញអាជីពជូនប្រជាជននៅតំបន់ជនបទចំនួន ២ ៧៨៦វគ្គ មានអ្នកចូលរួម ៥៣ ៦២០នាក់ លើជំនាញបច្ចេកទេសកសិកម្ម វិស្វកម្ម អេឡិចត្រូនិក និងសេវាកម្ម

- បានបោះពុម្ពផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានរបស់ក្រសួងចំនួន ២០លេខ បោះពុម្ពទិនានុលេខន៍ចំនួន ១០ឆ្នាំ និងរៀបចំឯកសារព័ត៌មាន និងផលិតវីដេអូព័ត៌មានសម្រាប់ផ្សាយតាមស្ថានីយ៍វិទ្យុ-ទូរទស្សន៍ចំនួន ១ ៤២១លើក។

**ឃ. ការងារអភិរក្ស និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច÷**

- បានចេញលិខិតទទួលស្គាល់អត្តសញ្ញាណជនជាតិដើមភាគតិចចំនួន ១៧៧សហគមន៍ក្នុងចំណោមសហគមន៍សរុបចំនួន ៤៥៥ និងបានរៀបចំកិច្ចប្រជុំពេញអង្គ ស្តីពីបទបញ្ជាផ្ទៃក្នុងចំនួន ៩៩ សហគមន៍ ក្នុងចំណោមសហគមន៍ ដែលបានទទួលស្គាល់សរុបចំនួន ១៧៧
- បានប្រារព្ធទិវាជាតិជនជាតិដើមភាគតិចចំនួន ១៩លើក និងសិក្ខាសាលាផ្សព្វផ្សាយគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិចចំនួន ១៦លើក និងសិក្ខាសាលាពង្រឹងតួនាទី និងរចនាសម្ព័ន្ធគណៈកម្មការសហគមន៍ជនជាតិដើមភាគតិចចំនួន ២លើក មានអ្នកចូលរួម ៦៧នាក់ ស្រី ២១ នាក់។

ដោយឡែកនៅក្នុងឆ្នាំ២០២៣ នេះ ក្រសួងម្រេចលទ្ធផលបាន ១០០% នៃផែនការ÷

**ក. ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ÷** អនុវត្តបាន ១០០% នៃផែនការ÷

- បានរៀបចំសិក្ខាសាលាចំនួន ៩លើក មានសិក្ខាកាម ៣១១នាក់ លើការងារសហគ្រាសខ្នាតតូច ទីផ្សារ ឥណទាន និងសហគមន៍សន្សំប្រាក់
- បានបណ្តុះបណ្តាលចំនួន ១៦វគ្គ មានសិក្ខាកាម ៣២៥នាក់ លើការងារផលិតសាប៊ូ សហគមន៍សន្សំប្រាក់ និងគំនិតផ្តួចផ្តើមអាជីវកម្ម
- បានសាងសង់ផ្សារបញ្ចប់ចំនួន ១កន្លែង នៅក្នុងខេត្តបាត់ដំបង និងរៀបចំការតាំងពិពណ៌ផលិតផលជនបទ ១លើក នៅក្នុងខេត្តតាកែវ។

**ខ. ការងារអភិវឌ្ឍន៍សហគមន៍÷** អនុវត្តបាន ១០០% នៃផែនការ÷

- បានបណ្តុះបណ្តាល គ.អ.ភ ចំនួន ៣៤វគ្គ ស្មើ ២០២ភូមិ មានអ្នកចូលរួម ចំនួន ៦៨០នាក់ ស្រី ២០៨នាក់ ក្នុខេត្តគោលដៅចំនួន ១២ខេត្ត គឺខេត្តព្រៃវែង សៀមរាប ត្បូងឃ្មុំ កំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ធំ កណ្តាល បន្ទាយមានជ័យ តាកែវ បាត់ដំបង ឧត្តរមានជ័យ និងខេត្តប៉ៃលិន
- បានបណ្តុះបណ្តាល ស្តីពីការត្រៀមបង្ការ និងកាត់បន្ថយគ្រោះភ័យក្នុងសហគមន៍ចំនួន ៦វគ្គ មានអ្នកចូលរួម ១២០នាក់ ស្រី ៥០នាក់ ក្នុងខេត្តបាត់ដំបង ប៉ៃលិន និងខេត្តបន្ទាយមានជ័យ និងបណ្តុះបណ្តាល ស្តីពីសួនដំណាំគ្រួសារ និងរបៀបធ្វើជីកំប៉ុស្ត ៦វគ្គ មានអ្នកចូលរួម ១២០នាក់ ស្រី ៨៩នាក់ នៅក្នុងខេត្តកែប និងខេត្តសៀមរាប
- ជីកស្រះគ្រួសារចំនួន ៥០ស្រះ ផ្តល់កូនឈើហូបផ្លែចម្រុះចំនួន ៤ 000ដើម ដល់ ៦៤០គ្រួសារ ផ្តល់ពូជបន្លែចម្រុះចំនួន ៩៥៥គ្រួសារ និងផ្តល់សម្ភារធ្វើរោងជីកំប៉ុស្តចំនួន ៣១៥គ្រួសារ។

**គ. ការងារបណ្តុះបណ្តាលធនធានមនុស្ស និងជំនាញអាជីព÷** អនុវត្តបាន ១០០% នៃផែនការ÷

– បានពង្រឹងសមត្ថភាពមន្ត្រី តាមរយៈវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សាក្នុងប្រទេសចំនួន ៧១៧លើក មានមន្ត្រីចូលរួមសរុប ៥ ២៩៦នាក់ និងក្រៅប្រទេសចំនួន ១៣លើក មានមន្ត្រីចូលរួមសរុប ២៧នាក់ ជាមធ្យមមន្ត្រី ១នាក់ទទួលបានការបណ្តុះបណ្តាល ៣-៤លើក/ឆ្នាំ
– បានផ្តល់ការបណ្តុះបណ្តាលជំនាញអាជីពជូនប្រជាជននៅតំបន់ជនបទចំនួន ១៤៧វគ្គ អ្នកចូលរួម ៣ ២៣៨នាក់ លើជំនាញបច្ចេកទេសកសិកម្ម វិស្វកម្ម អេឡិចត្រូនិក និងសេវាកម្ម
– បានបោះពុម្ពផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានរបស់ក្រសួងចំនួន ២លេខ និងផ្សព្វផ្សាយព័ត៌មានតាមវិទ្យុ និងទូរទស្សន៍ក្នុងស្រុកចំនួន ១៩៤លើក។

**ឃ. ការងារអភិរក្ស និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច÷** អនុវត្តបាន ១០០% នៃផែនការ÷

– បានចេញលិខិតទទួលស្គាល់អត្តសញ្ញាណជនជាតិដើមភាគតិចចំនួន ១៧សហគមន៍
– បានរៀបចំកិច្ចប្រជុំពេញអង្គបទបញ្ជាផ្ទៃក្នុងចំនួន ២សហគមន៍ និងរៀបចំទិវាជនជាតិដើមភាគតិចចំនួន ១លើក
– ពង្រឹងតួនាទី រចនាសម្ព័ន្ធគណៈកម្មការសហគមន៍ជនជាតិដើមភាគតិចចំនួន ២លើក មានអ្នកចូលរួម ៦៧នាក់ ស្រ្តី ២១នាក់។

ជារួម ការធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ គឺជាអភិក្រមមួយសម្រាប់ធានាប្រសិទ្ធភាព នៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ក្នុងគោលដៅបង្កើនប្រាក់ចំណូលបន្ថែម។ អភិក្រមនេះ ជាគន្លឹះក្នុងកៀរគរធនធាន និងកិច្ចសហការពីគ្រប់ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា ដើម្បីរួមកម្លាំងគ្នាលើកកម្ពស់ជីវភាពរស់នៅ ក៏ដូចជាការកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ការរស់នៅប្រកបដោយភាពសុខដុមនៅក្នុងសង្គមជនបទ។

## ២.៤. ពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅ

ក្រសួងបានបន្តយកចិត្តទុកដាក់យ៉ាងខ្លាំងលើការពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចទូទៅ ដើម្បីធានាប្រសិទ្ធភាព នៃការគ្រប់គ្រងរដ្ឋបាល និងការអនុវត្តផែនការ និងថវិកា នៃកម្មវិធីអភិវឌ្ឍន៍ជនបទឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។ ជាមួយគ្នានេះ ក្រសួងក៏បានបន្តចូលរួមអនុវត្ត និងគាំទ្រកម្មវិធីកែទម្រង់នានារបស់រាជរដ្ឋាភិបាលដូចជា កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងកម្មវិធីកែទម្រង់ផ្សេងៗទៀត ដែលជាការរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិឱ្យកាន់តែរីកចម្រើនឆ្ពោះទៅសម្រេចបានចក្ខុវិស័យឆ្នាំ ២០៣០ និងឆ្នាំ២០៥០។

ក្នុងន័យនេះ ក្រសួងបានរៀបចំផែនការវិនិយោគសាធារណៈបីឆ្នាំរំកិល (PIP) ២០២១-២០២៣

ដោយបានលើកជាគម្រោងវិនិយោគសរុបចំនួន ៤០គម្រោង មានទឹកប្រាក់សរុបចំនួន ៤៦៣ ១៦៩ ៨០០ ដុល្លារអាមេរិក ក្នុងនោះគម្រោងទទួលបានការគាំទ្រ និងកំពុងដំណើរការចំនួន ១៨គម្រោង គិតជាថវិកាសម្រាប់រយៈពេល ៣ឆ្នាំ (២០២១-២០២៣) សរុបចំនួន៣៨០ ៨០៩ ៨០០ដុល្លារអាមេរិក បើគិតជាថវិកាសម្រាប់តែឆ្នាំ ២០២៣ មានចំនួន ១៤៥ ៦២៨ ៥០០ដុល្លារអាមេរិក។

នៅក្នុងឆ្នាំ២០២៣ នេះ ការរៀបចំផែនការ និងការគ្រប់គ្រងថវិកា មានភាពល្អប្រសើរស្របតាមគោលការណ៍ណែនាំ ក៏ដូចជាបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាល។ ជាលទ្ធផល ក្រសួងបានអនុវត្តកម្មវិធីពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅសម្រេចលទ្ធផលបាន ៩៨% នៃផែនការ÷

**ក. ការរៀបចំផែនការសកម្មភាព និងថវិកា÷** អនុវត្តបាន ៩៧% នៃផែនការ÷

- បានរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ (២០២៤-២០២៦) ដោយបានធ្វើសមាហរណកម្មថវិកាមូលធន និងថវិកាចរន្តបញ្ចូលគ្នាតាមកម្មវិធីទាំង៤ របស់ក្រសួងស្របតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានរៀបចំសៀវភៅគោលការណ៍ណែនាំស្តីពី ការគ្រប់គ្រងថវិកាសមិទ្ធកម្មឆ្នាំ២០២៣ ដើម្បីធានាការអនុវត្តថវិកាឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ព្រមទាំងរក្សាបានតុល្យភាពនៃលំហូរសាច់ប្រាក់សម្រាប់ការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ
- បានបង្កើតក្រុមការងារថវិកា ដើម្បីផ្តល់ការណែនាំលើការរៀបចំ និងការបែងចែកកញ្ចប់ថវិកាទៅតាមកម្មវិធីអាទិភាពនីមួយៗរបស់ក្រសួង
- បានរៀបចំសិក្ខាសាលាពាក់ព័ន្ធនឹងការងាររៀបចំផែនការ និងប្រើប្រាស់ថវិកាចំនួន ៨លើក ចុះពង្រឹងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងប្រមូលទិន្នន័យស្ថិតិវិស័យអភិវឌ្ឍន៍ជនបទ តាមមន្ទីរអភិវឌ្ឍន៍ជនបទ រាជធានី-ខេត្ត ចំនួន ៨៤លើក
- បានរៀបចំកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងអង្គការមិនមែនរដ្ឋាភិបាល និងក្រសួងអភិវឌ្ឍន៍ជនបទបានចំនួន ៤៦កិច្ចព្រមព្រៀង និងបានរៀបចំសិក្ខាសាលាណែនាំ ស្តីពីការត្រួតពិនិត្យលទ្ធផលរបស់អង្គការក្រៅរដ្ឋាភិបាលចំនួន ២លើក។

**ខ. សេវាគាំទ្រ និងការងារគ្រប់គ្រងថវិកា÷** អនុវត្តបាន ១០០ % នៃផែនការ÷

- បានរៀបចំសិក្ខាសាលា ស្តីពីការផ្សព្វផ្សាយលទ្ធផលនៃការអនុវត្តថវិកាកម្មចំនួន ១វគ្គ មានអ្នកចូលរួម ១៨០នាក់ ស្រី ៥៧នាក់ និងសិក្ខាសាលាស្តីពីការពង្រឹងការប្រើប្រាស់ប្រព័ន្ធ FMIS និងប្រព័ន្ធ SARMIS ចំនួន ១វគ្គ មានអ្នកចូលរួម ១៧៥នាក់ ស្រី ៣៧នាក់
- បានចុះពង្រឹងការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងផ្ទៀងផ្ទាត់បញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋនៅមន្ទីរអភិវឌ្ឍន៍ជនបទចំនួន ២៥រាជធានី-ខេត្ត
- បានចុះត្រួតពិនិត្យប្រសិទ្ធភាព នៃការប្រើប្រាស់ថវិកាកម្មវិធីនៅមន្ទីរអភិវឌ្ឍន៍ជនបទទាំង ២៥

- បានផ្តល់ជូនសេវាគាំទ្ររដ្ឋបាល និងហិរញ្ញវត្ថុសម្រាប់ការអនុវត្តគោលនយោបាយរបស់ក្រសួង សម្រាប់រយៈពេល ១២ខែ, ការថែទាំ និងជួសជុលអគារទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ, ការផ្គត់ផ្គង់សម្ភារបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា និងសម្ភារបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា
- បានរៀបចំសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ ២០២៣ ចំនួន ១លើក ដែលមានអ្នកចូលរួមចំនួន ៦៥០នាក់ ស្រី ១៣៦នាក់ ។

**គ. ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច÷** អនុវត្តបាន ៩៧ % នៃផែនការ÷

- បានចុះធ្វើសវនកម្មនៅអង្គភាពចំនួន ២៨អង្គភាព រួមមានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តចំនួន ២៤ នាយកដ្ឋានចំនួន ១ និងគម្រោងចំនួន ៣គម្រោង និងបានតាមដានការអនុវត្តអនុសាសន៍សវនកម្មនៅ ២៥ សវនដ្ឋាន រួមមានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តចំនួន ២៤ និងគម្រោងចំនួន ១គម្រោង
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ចំនួន ១លើក មានអ្នកចូលរួមចំនួន ៤០នាក់ ស្រី ៧នាក់ សម្រាប់មន្ត្រីរាជការ នៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្តសៀមរាប
- បានចុះធ្វើអធិការកិច្ចនៅតាមមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្ត ចំនួន ២២លើក និងបានចុះផ្សព្វផ្សាយនីតិវិធីអធិការកិច្ចបានចំនួន ២លើក។

**ឃ. ការងារគ្រប់គ្រងរដ្ឋបាល ជនមានពិការភាព និងយេនឌ័រ÷** អនុវត្តបាន៩៤% នៃផែនការ÷

- បានចុះត្រួតពិនិត្យ និងវាយតម្លៃការគ្រប់គ្រងរដ្ឋបាល និងបុគ្គលិកចំនួន ១៩លើក, បានបណ្តុះបណ្តាល ស្តីពីការពង្រឹងសមត្ថភាពមន្ត្រីរាជការក្នុងវិស័យអភិវឌ្ឍន៍ជនបទចំនួន ៣លើក មានអ្នកចូលរួមចំនួន ២៦០នាក់ ស្រី ៥៣នាក់, បានធ្វើសិក្ខាសាលាផ្សព្វផ្សាយពីគោលការណ៍ណែនាំ បទបញ្ជាផ្ទៃក្នុងរបស់ក្រសួង និងនីតិវិធីគ្រប់គ្រងរដ្ឋបាល និងបុគ្គលិកចំនួន ១០លើក
- បានរៀបចំដំឡើងថ្នាក់ និងឋានន្តរស័ក្តិថ្នាក់ប្រចាំឆ្នាំ ថ្នាក់កិត្តិយសមុនចូលនិវត្តន៍ និងតាមកម្រិតសញ្ញាបត្រ ជូនមន្ត្រីរាជការ ចំនួន ៤៤៦នាក់ ស្រី ១៧២នាក់ និងបានរៀបចំផ្តល់គ្រឿងឥស្សរិយសជូនមន្ត្រីរាជការចំនួន ២៣៧នាក់ ស្រី ៧៤នាក់ ព្រមទាំងបានរៀបចំប័ណ្ណសរសើរជូនអង្គភាពក្រោមឱវាទក្រសួងចំនួន ៣៩អង្គភាព
- បានស្នើសុំតែងតាំង និងប្រគល់ភារកិច្ច ជូនមន្ត្រីរាជការជាស្ត្រីទទួលបានតួនាទីក្នុងការសម្រេចចិត្តមានចំនួន ៧៤នាក់
- បានរៀបចំសេចក្តីសម្រេចបង្កើតគណៈកម្មការ និងក្រុមការងារបច្ចេកទេសចំនួន ៣០ ដើម្បីជាយន្តការសម្រាប់គាំទ្រ និងពង្រឹងសមត្ថភាពស្ថាប័ន។

**ង. ការងារព័ត៌មានវិទ្យា និងបរិវត្តកម្មឌីជីថល÷**

ក្រសួងបានបង្កើតក្រុមការងារព័ត៌មានវិទ្យា និងឌីជីថល ដើម្បីរួមចំណែកអនុវត្តគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា២០២២-២០៣៥ និងគាំទ្រយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល តាមរយៈបណ្តុះបណ្តាលធនធានមនុស្ស និងការពង្រឹងសមត្ថភាពស្ថាប័ន ក្នុងគោលដៅបម្រើការងារអភិវឌ្ឍន៍ជនបទ ស្របតាមគោលនយោបាយឌីជីថល។

**ច. ការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ៖** ក្រសួងបានផ្ទេរមុខងារក្នុងវិស័យអភិវឌ្ឍន៍ជនបទចំនួន ៣មុខងារ ទៅឱ្យរដ្ឋបាលក្រុង-ស្រុក-ខណ្ឌ នៅទូទាំងប្រទេសចាប់ពីឆ្នាំ២០២០ (សេចក្តីសម្រេចលេខ ២២០/១៩ ក.អ.ជ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩)៖ ១.មុខងារផ្តល់សេវាអនាម័យជនបទរួមមាន៖ ការបំផុសឱ្យបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល និងការសាងសង់ ជួសជុល ថែទាំបង្គន់អនាម័យសាធារណៈ ២.មុខងារថែទាំ និងជួសជុលសំណង់ផ្គត់ផ្គង់ទឹកស្អាតជនបទគ្រប់ប្រភេទ និង៣.មុខងារថែទាំផ្លូវលក្ខណៈប្រចាំ ចំពោះផ្លូវ ដែលតភ្ជាប់ពីភូមិទៅភូមិ និងផ្លូវក្នុងភូមិគ្រប់ប្រភេទ លើកលែងតែផ្លូវក្រាលកៅស៊ូ និងផ្លូវបេតុង។ ជាក់ស្តែងក្រសួងបានអនុវត្តការផ្ទេរមុខងារទាំង ៣ ដល់ខេត្តមួយចំនួន ដូចខាងក្រោម៖ 3

- មុខងារផ្តល់សេវាអនាម័យជនបទចំនួន ១៥ស្រុក នៅក្នុងខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ និងខេត្តត្បូងឃ្មុំ
- មុខងារថែទាំ និងជួសជុលសំណង់ផ្គត់ផ្គង់ទឹកស្អាតជនបទគ្រប់ប្រភេទចំនួន ១១ស្រុក នៅក្នុងខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ ត្បូងឃ្មុំ និងខេត្តកំពត
- មុខងារថែទាំផ្លូវលក្ខណៈប្រចាំចំនួន ៧ស្រុក នៅក្នុងខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ និងខេត្តត្បូងឃ្មុំ។

សរុបរួមក្រសួងបានអនុវត្តកម្មវិធីអាទិភាពទាំង៤ ខាងលើ ដោយអនុវត្តផែនការថវិកាបាន៩៨% និងសម្រេចគោលដៅបាន ៩៨% ធៀបនឹងសូចនាករ និងគោលដៅសមិទ្ធកម្ម នៃកម្មវិធីដូចខាងក្រោម៖

| | | |
|---|---|---|
| កម្មវិធីទី១៖ | ប្រើប្រាស់ថវិកាបាន ៩៨% | សម្រេចគោលដៅ បានចំនួន ៩៧% |
| កម្មវិធីទី២៖ | ប្រើប្រាស់ថវិកាបាន ៩៧% | សម្រេចគោលដៅ បានចំនួន ៩៨% |
| កម្មវិធីទី៣៖ | ប្រើប្រាស់ថវិកាបាន ៩៨% | សម្រេចគោលដៅ បានចំនួន ១០០% |
| កម្មវិធីទី៤៖ | ប្រើប្រាស់ថវិកាបាន ៩៦% | សម្រេចគោលដៅ បានចំនួន ៩៨%។ |

## ៣. បញ្ហាប្រឈម

ទន្ទឹមនឹងការសម្រេចបានសមិទ្ធផលជាច្រើនខាងលើ ក្រសួងក៏បាន និងកំពុងជួបប្រទះនូវបញ្ហា និងការប្រឈមមួយចំនួន នៅក្នុងដំណើរការ នៃការអភិវឌ្ឍ ដែលទាមទារឱ្យមានការដោះស្រាយជាប្រព័ន្ធប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការជាក់ស្តែងរបស់ប្រជាជននៅតំបន់ជនបទ ក្នុងគោលបំណងលើកកម្ពស់ជីវភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ប្រកបដោយប្រសិទ្ធភាព និងមាននិរន្តរភាព។

**ក. បញ្ហា**

- ការដឹកជញ្ជូនលើសទម្ងន់កំណត់ និងការកែឆ្នៃរថយន្តខុសបទដ្ឋានបច្ចេកទេស បាន និងកំពុងបង្កឱ្យខូចផ្លូវយ៉ាងឆាប់រហ័ស
- ការកាន់កាប់ដីចំណីផ្លូវរបស់ប្រជាពលរដ្ឋធ្វើឱ្យមានភាពស្មុគស្មាញដល់ការងារស្តាបនា និងកែលម្អផ្លូវជនបទ ពីព្រោះពិបាកក្នុងការពង្រីកផ្លូវឱ្យសមស្របតាមតម្រូវការប្រើប្រាស់ ដោយសារត្រូវចំណាយពេលវេលា និងថវិកាច្រើនក្នុងការដោះស្រាយផលប៉ះពាល់
- នៅតំបន់ខ្លះ ខ្វះវត្ថុធាតុដើម និងពិបាករក (គុណភាពដី និងថ្ម) សម្រាប់ការងារសាងសង់ផ្លូវ ដែលនាំឱ្យតម្លៃសាងសង់កើនឡើង ដោយសារតម្លៃថ្លៃ និងត្រូវដឹកជញ្ជូនពីទីតាំងឆ្ងាយៗ
- តំបន់ដាច់ស្រយាលមួយចំនួន នៅមិនទាន់បានទទួលសេវាផ្គត់ផ្គង់ទឹកស្អាត អប់រំសុខភាព អនាម័យ និងបរិស្ថានពេញលេញនៅឡើយ
- ប្រជាពលរដ្ឋនៅតំបន់ជនបទមួយចំនួនមានកម្រិតជីវភាពទាប ត្រូវការដោះស្រាយជីវភាពប្រចាំថ្ងៃចំពោះមុខ និងមិនចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍
- ប្រជាពលរដ្ឋខ្វះការសហការគ្នាក្នុងការផលិតសម្រាប់ផ្គត់ផ្គង់តម្រូវការទីផ្សារ និងខ្វះកិច្ចសហការពីគ្រប់ភាគីពាក់ព័ន្ធ ដើម្បីរួមគ្នាគាំទ្រដល់ដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ចជនបទ
- មិនទាន់មានកិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេស និងផ្នែកហិរញ្ញវត្ថុពីគ្រប់ភាគីពាក់ព័ន្ធ ជាអាទិ៍ គ្រឹះស្ថានសាធារណៈ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានា ដើម្បីគាំទ្រលើការងារបណ្តុះបណ្តាល និងស្រាវជ្រាវ ទាំងក្របខ័ណ្ឌមន្ត្រីរាជការ និងជំនាញមូលដ្ឋានសម្រាប់ប្រជាពលរដ្ឋនៅតំបន់ជនបទ ។

**ខ. ការប្រឈម**

- មិនទាន់មានគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទ សម្រាប់រយៈពេលវែង
- មិនទាន់មានលិខិតបទដ្ឋានគតិយុត្ត និងទោសប្បញ្ញត្តិ ដើម្បីគ្រប់គ្រងបទល្មើស នៃការដឹកជញ្ជូនលើសទម្ងន់លើផ្លូវជនបទ និងសម្រាប់ការគ្រប់គ្រងដីចំណីផ្លូវជនបទ
- បន្ទុក នៃការចំណាយលើការងារសាងសង់ ជួសជុល និងស្ថាបនាផ្លូវកាន់តែកើនឡើងខ្ពស់ដោយសារកំណើនតម្លៃវត្ថុធាតុដើម និងការដឹកជញ្ជូនឆ្ងាយ
- ការប្រែប្រួលអាកាសធាតុ បាន និងកំពុងធ្វើឱ្យប៉ះពាល់លើហេដ្ឋារចនាសម្ព័ន្ធជនបទ ដែលទាមទារឱ្យមានការគិតគូរលើការបង្កើនថវិកាវិនិយោគ ដើម្បីធានាភាពធន់
- ជួបការលំបាកខ្លាំងក្នុងការសម្រេចឱ្យបានតាមគោលដៅ នៃការផ្គត់ផ្គង់ទឹក និងអនាម័យជនបទនៅឆ្នាំ២០៣០ ដោយតំបន់មួយចំនួនស្ថិតនៅដាច់ស្រយាលពិបាកទៅដល់
- ខ្វះមធ្យោបាយ និងធនធានសម្រាប់គាំទ្រដល់សហគមន៍ជនបទ ក្នុងការផលិត និងបង្កើតមុខរបរសមស្របនៅតាមទីជនបទ

- ខ្វះការយល់ដឹង និងចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍សហគមន៍របស់ប្រជាពលរដ្ឋនៅតំបន់ជនបទ ដើម្បីលើកកម្ពស់ជីវភាពសម្រាប់រយៈពេលវែង
- ខ្វះកិច្ចសហប្រតិបត្តិការពីគ្រប់ភាគីពាក់ព័ន្ធ រួមទាំងវិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានា ក្នុងការងារបណ្តុះបណ្តាល និងស្រាវជ្រាវពីតម្រូវការ ទាំងក្របខ័ណ្ឌមន្ត្រីរាជការ និងជំនាញមូលដ្ឋានសម្រាប់ប្រជាពលរដ្ឋនៅជនបទ
- ជួបការលំបាកក្នុងការសម្របសម្រួលជាមួយភាគីពាក់ព័ន្ធលើការងារអភិវឌ្ឍន៍នៅតាមតំបន់ ដែលមានជនជាតិដើមភាគតិចរស់នៅ ដោយសារកត្តាភូមិសាស្ត្រដាច់ស្រយាល និងបែបផែនជីវិត នៃការរស់នៅមានសភាពរាយប៉ាយ។

## ៤. ទិសដៅការងារបន្ត

ផ្អែកលើលទ្ធផលការងារក្នុងឆ្នាំ២០២៣ និងដើម្បីចាត់វិធានការដោះស្រាយនូវបញ្ហា និងការប្រឈម របស់ក្រសួងអភិវឌ្ឍន៍ជនបទ បានដាក់ចេញនូវទិសដៅបន្តសម្រាប់អនុវត្តកម្មវិធីអាទិភាពទាំង៤ នៅក្នុងឆ្នាំ២០២៤ ដូចខាងក្រោម÷

### ៤.១.កម្មវិធីទី១

**អនុកម្មវិធីទី១÷ ការជួសជុល និងរក្សាគុណភាពផ្លូវជនបទ**

- បន្តការថែទាំផ្លូវជាលក្ខណៈខួប
- បន្តការថែទាំផ្លូវជាលក្ខណៈប្រចាំ
- បន្តត្រៀមជួសជុលផ្លូវជាលក្ខណៈបន្ទាន់
- រៀបចំផែនការសម្រាប់ការជួសជុល និងថែទាំផ្លូវទូទាំងរាជធានី-ខេត្ត
- ការចុះត្រួតពិនិត្យ និងវាយតម្លៃការជួសជុល និងរក្សាគុណភាពផ្លូវជនបទ

**អនុកម្មវិធីទី២÷ ការពង្រីកវិសាលភាពនៃការស្ថាបនា លើកកម្រិតហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ**

- បន្តការស្ថាបនា និងកែលម្អផ្លូវជនបទ
- បន្តការស្ថាបនាសំណង់សិល្បការ្យ
- បន្តការរាប់ចំនួនចរាចរណ៍
- រៀបចំផែនការ ស្វែងរកវត្ថុធាតុដើម និងបច្ចេកវិទ្យាសមស្រប សម្រាប់ការស្ថាបនាលើកកម្រិតហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ
- ការចុះត្រួតពិនិត្យ និងវាយតម្លៃការស្ថាបនាលើកកម្រិតហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ
- បន្តពង្រឹងសមត្ថភាពមន្ទីរពិសោធន៍

**អនុកម្មវិធីទី៣. ការរៀបចំបញ្ជីសារពើភ័ណ្ឌ និងមូលដ្ឋានទិន្នន័យផ្លូវជនបទ**

- បន្តការរៀបចំបញ្ជីសារពើភ័ណ្ឌផ្លូវជនបទតាមរយៈការធ្វើបច្ចុប្បន្នភាពជាប្រចាំ
- បន្តការរៀបចំផែនទីផ្លូវជនបទតាមរយៈការធ្វើបច្ចុប្បន្នភាពជាប្រចាំដោយប្រើប្រាស់ RRAMS (Rural Road Asset Management System )

- បណ្តុះបណ្តាលការប្រើប្រាស់ RRAMS ដល់មន្ត្រីបច្ចេកទេសរបស់មន្ទីរអភិវឌ្ឍន៍ជនបទ រាជធានី-ខេត្តទាំង២៥
- បន្តធ្វើផែនទីតំបន់រងហានិភ័យតាមរយៈការធ្វើបច្ចុប្បន្នភាពជាប្រចាំ
- រៀបចំកម្មវិធី(App) សម្រាប់ផ្តល់ និងទទួលព័ត៌មានអំពីផ្លូវជនបទ

**អនុកម្មវិធីទី៤.ការផ្តល់សេវាហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តជនបទដោយមន្ទីរជំនាញ ២៥**

- មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្តទាំង២៥ បន្តផ្តល់សេវាហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តជនបទ

### ៤.២.កម្មវិធីទី២

**អនុកម្មវិធីទី១÷ការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតជនបទ**

- បន្តការសាងសង់អណ្តូងទឹកធន់នឹងការប្រែប្រួលអាកាសធាតុ
- បន្តការសាងសង់ប្រភពទឹកស្អាតជនបទ
- បន្តការសាងសង់ និងស្តារប្រព័ន្ធស្រោចស្រពខ្នាតតូច

**អនុកម្មវិធីទី២÷ការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ទឹកស្អាតជនបទ**

- បន្តការបណ្តុះបណ្តាលបច្ចេកទេសថែទាំ និងជួសជុលអណ្តូងទឹក
- បន្តការអប់រំប្រជាពលរដ្ឋយល់ដឹងពីការប្រើប្រាស់ទឹកស្អាត
- បន្តការប្រារព្ធទិវាទឹកពិភពលោក
- បន្តការរៀបចំផែនការសុវត្ថិភាពទឹក
- បន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារទឹកស្អាតជនបទ
- រៀបចំគ្រប់គ្រងទិន្នន័យនៃការផ្គត់ផ្គង់ទឹកស្អាតជនបទតាមប្រព័ន្ធព័ត៌មានវិទ្យា
- ពង្រឹងមន្ទីរពិសោធន៍ត្រួតពិនិត្យគុណភាពទឹកជនបទ

**អនុកម្មវិធីទី៣÷ការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តអនាម័យជនបទ**

- បន្តការសាងសង់បង្គន់អនាម័យសម្រាប់ប្រជាជនជនបទ
- សិក្សាត្រៀមរៀបចំការគ្រប់គ្រងកាកសំណល់លាមកនៅតំបន់ជនបទ
- សិក្សាស្រាវជ្រាវបច្ចេកវិទ្យាសមស្របសម្រាប់សាងសង់បង្គន់អនាម័យក្នុងតំបន់ដែលមានបរិស្ថានប្រឈម

**អនុកម្មវិធីទី៤÷ការលើកកម្ពស់ការរស់នៅស្អាត ការអប់រំសុខភាព និងអនាម័យជនបទ**

- បន្តការពង្រឹងសមត្ថភាពស្ថាប័នក្នុងការលើកកម្ពស់ការរស់នៅស្អាត និងអនាម័យ ជនបទ
- បន្តបង្កើនការប្រើប្រាស់បង្គន់អនាម័យ ដែលមានការកែលម្អប្រកបដោយនិរន្តរភាព
- បន្តលើកកម្ពស់ការផ្លាស់ប្តូរឥរិយាបថ ការរស់នៅស្អាត និងអនាម័យ
- បន្តការអប់រំផ្សព្វផ្សាយអំពីការលើកកម្ពស់សុខភាព ការរស់នៅស្អាត និងអនាម័យជនបទ
- បន្តការងារអប់រំអំពីជំងឺឆ្លង និងសុខភាពបន្តពូជ
- រៀបចំគ្រប់គ្រងទិន្នន័យអនាម័យជនបទតាមប្រព័ន្ធព័ត៌មានវិទ្យា
- បន្តរៀបចំទិវាជាតិលើកកម្ពស់អនាម័យជនបទ និងទិវាលាងសម្អាតដៃពិភពលោក
- បន្តរៀបចំប្រកាសទទួលស្គាល់ក្រុង -ស្រុក-ខណ្ឌ, រាជធានី-ខេត្ត ដែលបញ្ចប់ការបន្ទោរបង់

ពាសវាលពាសកាល (ODF)

**អនុកម្មវិធីទី៥÷ការផ្តល់សេវាសុខភាព និងលក្ខខ័ណ្ឌនៃការរស់នៅសម្រាប់សាធារណជន ដោយមន្ទីរជំនាញ ២៥**

- មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្តទាំង២៥ បន្តផ្តល់សេវាសុខភាព និងលក្ខខ័ណ្ឌនៃការរស់នៅសម្រាប់សាធារណជន

**៤.៣.កម្មវិធីទី៣**

**អនុកម្មវិធីទី១÷ការជំរុញបង្កើតការងារ និងមុខរបរនៅជនបទ**

- បន្តស្វែងរកគំនិតផ្តួចផ្តើមបង្កើតអាជីវកម្មខ្នាតតូច និងគ្រួសារ
- បន្តគ្រប់គ្រង និងពង្រឹងសមត្ថភាពមជ្ឈមណ្ឌលអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ស្ថិតក្នុងភូមិស្វាយអំពារ ឃុំស្វាយអំពារ ស្រុកមុខកំពូល ខេត្តកណ្តាល
- បន្តជំរុញ និងគាំទ្រការកែច្នៃផលិតផលសហគមន៍ជនបទ និងចលនាភូមិមួយផលិតផលមួយ
- បន្តគាំទ្រសកម្មភាពសហគមន៍សន្សំប្រាក់ដែលមានស្រាប់ និងបង្កើតថ្មី
- បន្តការបណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈទីផ្សារ និងការគ្រប់គ្រងអាជីវកម្មខ្នាតតូច
- បន្តបណ្តុះបណ្តាលសហគ្រិនភាពដល់គ្រួសារជនបទ

**អនុកម្មវិធីទី២.ការជំរុញសកម្មភាពសេដ្ឋកិច្ចគ្រួសារនៅជនបទ**

- បន្តជំរុញការផ្សព្វផ្សាយផលិតផលសម្រេចរបស់សហគមន៍
- បន្តរៀបចំសិក្ខាសាលាស្វែងរកទីផ្សារជូនផលិតករសហគមន៍
- បន្តការរៀបចំបង្កើតផ្សារជនបទ
- បន្តគាំទ្រការងារឥណទាននៅសហគមន៍ជនបទ
- បន្តរៀបចំពិព័រណ៌ផលិតផលសហគមន៍ជនបទ

**អនុកម្មវិធីទី៣÷ការបណ្តុះបណ្តាលធនធានមនុស្ស និងជំនាញអាជីព**

- បន្តការស្រាវជ្រាវ និងផលិតព្រឹត្តិប័ត្រព័ត៌មានការងារអភិវឌ្ឍន៍ជនបទ
- បន្តការបណ្តុះបណ្តាលបំណិនជីវិតដល់ប្រជាពលរដ្ឋជនបទ
- បន្តការរៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូបង្គោល
- បន្តសកម្មភាពបណ្តុះបណ្តាលជំនាញមូលដ្ឋានចល័តតាមតំបន់ជនបទ
- បន្តបណ្តុះបណ្តាលជំនាញអាជីពមូលដ្ឋាននៅមជ្ឈមណ្ឌលទាំង ១១ខេត្ត

**អនុកម្មវិធីទី៤÷ជំរុញការអភិវឌ្ឍចម្រុះសម្រាប់សហគមន៍ជនបទ**

- បន្តពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ)
- បន្តអភិវឌ្ឍភូមិចម្រុះ គាំទ្រភូមិគំរូដែលមានស្រាប់ និងសិក្សារៀបចំបង្កើតភូមិគំរូថ្មី
- បន្តលើកកម្ពស់សន្តិសុខស្បៀងជាលក្ខណៈគ្រួសារ
- បន្តគាំទ្រសកម្មភាពអប់រំក្រៅប្រព័ន្ធដល់ប្រជាពលរដ្ឋក្នុងសហគមន៍
- បន្តគាំទ្រសកម្មភាពមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា-កូរ៉េ
- បន្តគាំទ្រសកម្មភាពមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ខេត្តតាកែវ និងខេត្តកំពង់ស្ពឺ

**អនុកម្មវិធីទី៥÷ការអភិវឌ្ឍ និងអភិរក្សជនជាតិដើមភាគតិច**

- បន្តកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច
- បន្តពង្រឹងសមត្ថភាព និងអភិវឌ្ឍសហគមន៍ជនជាតិដើមភាគតិច
- បន្តរៀបចំសហគមន៍គំរូជនជាតិដើមភាគតិច
- បន្តរៀបចំទិវាអន្តរជាតិជនជាតិដើមភាគតិច
- រៀបចំប្រព័ន្ធព័ត៌មានភូមិសាស្ត្ររបស់សហគមន៍ជនជាតិដើមភាគតិច
- រៀបចំមជ្ឈមណ្ឌលអភិវឌ្ឍន៍ និងអភិរក្សវិជ្ជាជីវៈជនជាតិដើមភាគតិច
- រៀបចំចងក្រងផ្សព្វផ្សាយឯកសារ ស្ដីពីការងារអភិវឌ្ឍន៍ និងអភិរក្សជនជាតិដើមភាគតិច
- បន្តសហការរៀបចំទិន្នន័យប្រជាសាស្ត្រជនជាតិដើមភាគតិចឱ្យកាន់តែមានសង្គតិភាព
- បន្តផ្សព្វផ្សាយគោលនយោបាយជាតិដល់ភាគីពាក់ព័ន្ធស្ដីពីការអភិវឌ្ឍន៍ជនជាតិដើមភាគតិច

**អនុកម្មវិធីទី៦÷**ការលើកកម្ពស់កម្រិតជីវភាពរស់នៅតាមជនបទ ដោយមន្ទីរជំនាញទាំង២៥

- មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្តទាំង២៥ បន្តផ្ដល់លើកកម្ពស់កម្រិតជីវភាពរស់នៅតាមជនបទ

**៤.៤.កម្មវិធីទី៤**

**អនុកម្មវិធីទី១÷ការពង្រឹងគុណភាពប្រព័ន្ធគ្រប់គ្រងផែនការអភិវឌ្ឍន៍ជនបទ**

- បន្តរៀបចំផែនការថវិកាសមិទ្ធកម្មប្រចាំឆ្នាំ,ផែនការយុទ្ធសាស្ត្រថវិកាបីឆ្នាំរំកិល (២០២៥-២០២៧),ផែនការវិនិយោគសាធារណៈបីឆ្នាំរំកិល (២០២៥-២០២៧) និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទរយៈពេល ៥ ឆ្នាំ (២០២៤-២០២៨)
- បន្តធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិវិស័យអភិវឌ្ឍន៍ជនបទ
- បន្តបញ្ជ្រាបភាពធន់នឹងការប្រែប្រួលអាកាសធាតុក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ
- បន្តការគ្រប់គ្រងផ្សព្វផ្សាយព័ត៌មានវិស័យអភិវឌ្ឍន៍ជនបទ
- បន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធ
- ចុះតាមដាន ត្រួតពិនិត្យ និងវាយតម្លៃផែនការប្រចាំឆ្នាំ ដើម្បីរៀបចំរបាយការណ៍សមិទ្ធកម្ម

**អនុកម្មវិធីទី២÷ការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកាកម្មវិធី**

- បន្តផ្សព្វផ្សាយលទ្ធផលនៃការអនុវត្តថវិកាកម្មវិធី
- បន្តពង្រឹងប្រសិទ្ធភាពនៃការអនុវត្តថវិកាកម្មវិធី
- បន្តពង្រឹងការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បន្តពង្រឹងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា(FMIS)
- បន្តចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) ដោយ
- បង្កើតអង្គភាពថវិកាពេញលេញ និងរៀបចំកិច្ចព្រមព្រៀងសមិទ្ធកម្មជាមួយអង្គភាពប្រតិបត្តិ

**អនុកម្មវិធីទី៣÷ការបង្កើនប្រសិទ្ធភាពសវនកម្មផ្ទៃក្នុង និងអធិការកិច្ច**

- បន្តផ្សព្វផ្សាយអំពីប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង និងការងារសវនកម្មផ្ទៃក្នុង
- បន្តចុះធ្វើសវនកម្មទូទៅ សវនកម្មសមិទ្ធកម្ម និងសវនកម្មបច្ចេកវិទ្យាព័ត៌មាន
- បន្តចុះតាមដានការអនុវត្តតាមអនុសាសន៍សវនកម្មផ្ទៃក្នុង
- បន្តចុះអធិការកិច្ចតាមមន្ទីរអភិវឌ្ឍន៍ជនបទរាជធានីខេត្ត
- បន្តផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីអធិការកិច្ច
- ពង្រឹងសមត្ថភាពសវនករផ្ទៃក្នុង និងមន្ត្រីអធិការកិច្ច
- បន្តចុះធ្វើសវនកម្ម និង/ឬ អធិការកិច្ចតាមការណែនាំរបស់ប្រធានស្ថាប័ន ដើម្បីមានមូលដ្ឋានក្នុងការដោះស្រាយរាល់សំណូមពរ និងពាក្យបណ្តឹង

**អនុកម្មវិធីទី៤÷ការពង្រឹងប្រសិទ្ធភាពគ្រប់គ្រងរដ្ឋបាល និងយេនឌ័រ**

- បន្តផ្សព្វផ្សាយ និងបញ្ជ្រាបទស្សនៈយេនឌ័រ និងអនុសញ្ញាស៊ី-ដ ដល់អង្គភាពក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ
- បន្តតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការបញ្ជ្រាបយេនឌ័រ គ្រប់អង្គភាពក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ និងសហគមន៍គោលដៅ
- រៀបចំបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រយេនឌ័រ ៥ ឆ្នាំបន្ត (២០២៤-២០២៨)
- បន្តយកចិត្តទុកដាក់ និងលើកកម្ពស់ការចូលរួមរបស់ជនមានពិការភាពក្នុងវិស័យអភិវឌ្ឍន៍ជនបទ
- បន្តពង្រឹងការអនុវត្តកម្មវិធីកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអភិវឌ្ឍន៍ជនបទ
- បន្តពង្រឹងស្ថាប័នតាមរយៈការកែទម្រង់រដ្ឋបាលសាធារណៈក្នុងក្រសួងអភិវឌ្ឍន៍ជនបទ
- ធ្វើបរិវត្តកម្មឌីជីថល និងព័ត៌មានវិទ្យាក្នុងវិស័យអភិវឌ្ឍន៍ជនបទ

**អនុកម្មវិធីទី៥÷សេវាគាំទ្រគោលនយោបាយ**

- បន្តពង្រឹងសេវាគាំទ្ររដ្ឋបាល ហិរញ្ញវត្ថុ និងរៀបចំគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍជនបទ ២០២៥-២០៣៥ , គោលនយោបាយស្តីពីផ្លូវជនបទ, គោលនយោបាយស្តីពីការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យអភិវឌ្ឍន៍ជនបទ, គោលនយោបាយស្តីពីការអភិវឌ្ឍសហគមន៍ និងគោលនយោបាយផ្សេងៗទៀត
- គាំទ្រដល់ក្រុមការងាររៀបចំគោលនយោបាយ ឯកសារគតិយុត្ត និងកម្មវិធី/គម្រោងតាមរយៈលើកទឹកចិត្តទាំងស្មារតី សម្ភារ និងថវិកា
- បន្តរៀបចំ និងផ្សព្វផ្សាយលទ្ធផលសន្និបាតប្រចាំឆ្នាំរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បន្តការជួសជុល និងថែទាំអគាររដ្ឋបាលក្រសួងអភិវឌ្ឍន៍ជនបទ

- បន្តផ្គត់ផ្គង់សម្ភារ និងបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា
- បន្តផ្គត់ផ្គង់សម្ភារ និងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា

**អនុកម្មវិធីទី៦÷** ការពង្រឹងសមត្ថភាព និងសេវាគាំទ្រដោយមន្ទីររាជធានី ខេត្តទាំង ២៥

- មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្តទាំង២៥ បន្តពង្រឹងសមត្ថភាព និងសេវាគាំទ្រអង្គភាព

## ៥. សេចក្តីសន្និដ្ឋាន

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី បានសម្រេចនូវសមិទ្ធផលជាច្រើន ដែលជាមូលដ្ឋានសម្រាប់រាជរដ្ឋាភិបាលបន្តវេន ដែលដឹកនាំដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បាននាំមកនូវកំណើនសេដ្ឋកិច្ចក្នុងឆ្នាំ២០២៣ នេះ ទោះបីស្ថិតក្នុងបរិបទនៃវិបត្តិសកលជាបន្តបន្ទាប់យ៉ាងណាក៏ដោយ។ ភាពជោគជ័យដ៏ត្រចះត្រចង់នេះ គឺកើតចេញពីកត្តាសុខសន្តិភាព ស្ថិរភាពនយោបាយក្នុងប្រទេស គួបផ្សំនឹងភាពស៊ាំនឹងជំងឺកូវីដ-១៩ ផងដែរ តាមរយៈយុទ្ធនាការចាក់វ៉ាក់សាំងដ៏សកម្មបំផុតនៅទូទាំងប្រទេសនាពេលកន្លងមក ដែលបានបង្កលក្ខណៈឱ្យប្រជាជនមានលទ្ធភាពប្រកបរបរចញ្ចឹមជីវិតតាមប្រក្រតីភាព។

នៅឆ្នាំ២០២៣ នេះ ក្រសួងអភិវឌ្ឍន៍ជនបទ បានអនុវត្តកម្មវិធីអាទិភាពទាំង ៤ សម្រេចបានលទ្ធផលប្រមាណជា ៩៨% នៃផែនការប្រចាំឆ្នាំរួមមាន កម្មវិធីទី១.អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍ កម្មវិធីទី២.កែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ កម្មវិធីទី៣.ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ និងកម្មវិធីទី៤.ពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅ។ កម្មវិធីអាទិភាពទាំង៤នេះ គឺជាកាតាលីករយ៉ាងសំខាន់ក្នុងការរួមចំណែកជំរុញឱ្យសម្រេចបាននូវគោលបំណងគោលនយោបាយ ស្តីពីការលើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរស់នៅរបស់ប្រជាជនជនបទ ប្រកបដោយបរិយាបន្ន ទាំងផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដោយមានសង្គតិភាពជាមួយនឹងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល ដើម្បីកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។

ផ្អែកលើលទ្ធផលដ៏ធំធេងខាងលើ និងដោយមានកត្តារួមផ្សំជាច្រើន នៅឆ្នាំ២០២៤ ខាងមុខនេះ ក្រសួងអភិវឌ្ឍន៍ជនបទ នឹងបន្តរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទរយៈពេល ៥ឆ្នាំ សម្រាប់នីតិកាលទី៧ ឱ្យស្របទៅនឹងកម្មវិធីនយោបាយ យុទ្ធសាស្ត្រដ៏ត្រឹមត្រូវ និងឆ្លើយតបទៅនឹងសំណូមពររបស់ប្រជាពលរដ្ឋ ព្រមទាំងលើកកម្ពស់ឧត្តមប្រយោជន៍ជាតិ ដើម្បីប្រែក្លាយកម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងមានចំណូលខ្ពស់នៅឆ្នាំ២០៥០៕

**រដ្ឋមន្ត្រី**